# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

******

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៥.០៧៣/០៨ គ.ជ.ប.អគ្គ.ពស**

ភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៨

# គណបក្សសិទ្ធិមនុស្សត្រូវបានទទួលស្គាល់ជាផ្លូវការ ក្នុងការចុះបញ្ជី គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

នៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៨ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានសម្រេចទទួលស្គាល់ជាផ្លូវការនូវការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ ឆ្នាំ២០០៨ របស់គណបក្សសិទ្ធិមនុស្ស ។

យោងតាមពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ គណបក្សសិទ្ធិមនុស្សបានដាក់បញ្ជីបេក្ខជនឈរឈ្មោះនៅទូទាំង២៤ខេត្ត ក្រុង ដែលមានបេក្ខជនឈរឈ្មោះសរុបចំនួន ២៦៤ នាក់ ក្នុងនោះមានបេក្ខជនពេញសិទ្ធិចំនួន ១២៣ នាក់ និងបេក្ខជនបម្រុងចំនួន ១៤១ នាក់ ។

សូមបញ្ជាក់ថា សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ឆ្នាំ២០០៨នេះ មានគណបក្សនយោបាយចំនួន១២ បានចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ហើយក្នុងចំណោមគណបក្សនយោបាយទាំងនេះមានគណបក្សចំនួន៤ ដែល គ.ជ.ប បានសម្រេចទទួលស្គាល់ជាផ្លូវការគឺ :

| | | |
|---|---|---|
| ១- | គណបក្សប្រជាជនកម្ពុជា | ទទួលស្គាល់នៅថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០០៨ |
| ២- | គណបក្សនរោត្តម រណឫទ្ធិ | ទទួលស្គាល់នៅថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០០៨ |
| ៣- | គណបក្សហង្សដាវ៉ាចលនាប្រជាធិបតេយ្យ | ទទួលស្គាល់នៅថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០០៨ |
| ៤- | គណបក្សសិទ្ធិមនុស្ស | ទទួលស្គាល់នៅថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ២០០៨ |

រីឯគណបក្សសង្គមខ្មែរនិយម ត្រូវបានបដិសេធដោយសារមិនបានបំពេញតាមលក្ខខណ្ឌត្រឹមត្រូវ ដែលច្បាប់បានកំណត់ក្នុងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនោះ ហើយគណបក្សហ៊ុនស៊ិនប៊ុចត្រូវបាន គ.ជ.ប ចេញលិខិតឱ្យធ្វើការកែតម្រូវក្នុងរយៈពេលប្រាំថ្ងៃ ដោយគណបក្សនេះនៅខ្វះលក្ខខណ្ឌមួយចំណុចគឺ បេក្ខជនឈរឈ្មោះប្រាំរូបគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។ ដោយឡែកគណបក្សនយោបាយចំនួន៦ទៀត គ.ជ.ប កំពុងធ្វើការពិនិត្យ ហើយគណបក្សទាំងនោះគឺ : គណបក្សសង្គមយុត្តិធម៌ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គណបក្សសម រង្ស៊ី គណបក្សខ្មែរឈប់ក្រ គណបក្សប្រជាធិបតេយ្យខ្មែរ និងគណបក្សខ្មែរសាធារណរដ្ឋ ។

យោងតាមបទបញ្ជា និងនីតិវិធី ប្រការ១១.៥ ចែងថា "គណបក្សនយោបាយ ដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ហើយត្រូវបានបដិសេធដោយ គ.ជ.ប សាមីគណបក្សនយោបាយ ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេច" ។